ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០១១៣ ព.ណ.ឧ.ស.ប.ប្រក

# ប្រកាស
# ស្តីពី
# កំឡុងពេលដកខ្លួនពីកិច្ចសន្យា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._ គោលបំណង**

ប្រកាសនេះកំណត់អំពីក្របខណ្ឌគតិយុត្ត ផ្តល់សិទ្ធិឱ្យអ្នកប្រើប្រាស់អាចដកខ្លួនចេញពីកិច្ចសន្យាដោយឯកតោភាគី ក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យា ក្នុងគោលបំណងពង្រឹងនិងលើកកម្ពស់ការធ្វើធុរកិច្ចប្រកបដោយសុចរិត ដើម្បីបង្កើនទំនុកចិត្តនៅក្នុងទីផ្សារនៃការលក់ទំនិញ និង/ឬសេវាពីចម្ងាយ និងការលក់ទំនិញ និង/ឬសេវានៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់។

**ប្រការ២._ វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយណា ដែលធ្វើធុរកិច្ចលក់ទំនិញ និង/ឬសេវាពីចម្ងាយ និងធុរកិច្ចលក់ទំនិញ និង/ឬសេវានៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣._ និយមន័យ**

វាក្យស័ព្ទសំខាន់ៗមួយចំនួននៃប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

ក. **បុគ្គលធ្វើធុរកិច្ច** សំដៅដល់បុគ្គលទាំងឡាយណាដែលធ្វើធុរកិច្ច ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ខ. **ក្រមរដ្ឋប្បវេណី** សំដៅដល់ក្រមរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ និងការធ្វើវិសោធនកម្ម ឬការជំនួសក្រោយៗមកទៀត។

គ. **កំឡុងពេលដកខ្លួនពីកិច្ចសន្យា** សំដៅដល់កំឡុងពេលមួយដែលកំណត់ដោយប្រកាសនេះ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចដកខ្លួនពីកិច្ចសន្យាផ្គត់ផ្គង់ទំនិញ និង/ឬសេវា បន្ទាប់ពីទទួលបាននូវទំនិញ និង/ឬសេវានោះ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលធ្វើធុរកិច្ច ទោះបីជាការផ្គត់ផ្គង់ទំនិញ និង/ឬសេវានោះ អនុលោមតាមលក្ខខណ្ឌនៃកិច្ចសន្យាក៏ដោយ។

ឃ. **អ្នកប្រើប្រាស់** មានអត្ថន័យដូចបានកំណត់នៅក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ង. **ការលក់ពីចម្ងាយ** សំដៅដល់ប្រតិបត្តិការនៃការលក់ទិញទំនិញ និង/ឬសេវា ដែលប្រព្រឹត្តទៅដោយមិនផ្ទាល់ និងមិនមានវត្តមានបុគ្គលតទល់មុខគ្នានៅទីតាំងរបស់បុគ្គលធ្វើធុរកិច្ច រួមបញ្ចូលទាំងការលក់តាមវិទ្យុ ទូរទស្សន៍ ទូរស័ព្ទ ទូរសារ កាតាឡុក កាសែត ទស្សនាវដ្តី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ខិត្តប័ណ្ណផ្សព្វផ្សាយ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការលក់ពីចម្ងាយផ្សេងទៀត ដែលអ្នកប្រើប្រាស់ពុំមានឱកាសក្នុងការពិនិត្យទំនិញ និង/ឬសេវា។

ច. **ការលក់នៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់** សំដៅដល់ប្រតិបត្តិការនៃការលក់ទិញទំនិញ និង/ឬសេវា ដែលបុគ្គលធ្វើធុរកិច្ច (រួមបញ្ចូលទាំងនិយោជិត ភ្នាក់ងារ និងអ្នកតំណាងរបស់បុគ្គលធ្វើធុរកិច្ច) បានលក់នៅគេហដ្ឋាន កន្លែងធ្វើការរបស់អ្នកប្រើប្រាស់ ទីសាធារណៈ ឬទីតាំងណាមួយ ដែលមិនមែនជាទីតាំងរបស់បុគ្គលធ្វើធុរកិច្ច។

ឆ. **ទំនិញ** សំដៅដល់គ្រប់ចលនវត្ថុទាំងអស់ រួមបញ្ចូលទាំងវត្ថុរូបីនិងអរូបី លើកលែងតែរូបិយប័ណ្ណ រូបិយវត្ថុ និងអចលនវត្ថុ។

ជ. **សេវា** មានអត្ថន័យដូចបានកំណត់នៅក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ឈ. **ថ្លៃលក់** សំដៅដល់ចំនួនទឹកប្រាក់ដែលបានព្រមព្រៀងគ្នាសម្រាប់ទូទាត់លើការលក់ទំនិញ និង/ឬសេវា។

ញ. **ការផ្គត់ផ្គង់ច្រើនលើក** មានអត្ថន័យដូចដែលបានកំណត់នៅក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ដ. **ការផ្គត់ផ្គង់** មានអត្ថន័យដូចដែលបានកំណត់នៅក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

**ប្រការ៤._ ស្ថាប័នមានសមត្ថកិច្ច**

ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តប្រកាសនេះ គឺគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ដែលហៅកាត់ថា គ.ជ.ក.ប. ដោយមានអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ដែលហៅកាត់ថា ក.ប.ប. ជាសេនាធិការ។

## ជំពូកទី២
## សិទ្ធិទទួលបានកំឡុងពេលដកខ្លួនពីកិច្ចសន្យាសម្រាប់ការលក់ពីចម្ងាយ

**ប្រការ៥._ សិទ្ធិដកខ្លួនរបស់អ្នកប្រើប្រាស់ពីកិច្ចសន្យាលក់ទិញពីចម្ងាយ**

១. ដើម្បីឱ្យអ្នកប្រើប្រាស់មានឱកាសពិនិត្យទំនិញ និង/ឬសេវា ដែលបានទិញតាមរយៈការលក់ពីចម្ងាយស្របតាមការអនុវត្តធុរកិច្ចសុចរិត បុគ្គលធ្វើធុរកិច្ចនៃការលក់ពីចម្ងាយត្រូវកំណត់លក្ខខណ្ឌនៅក្នុងកិច្ចសន្យាលក់ទិញ ដោយអនុញ្ញាតឱ្យអ្នកប្រើប្រាស់មានសិទ្ធិដកខ្លួនពីកិច្ចសន្យាដោយឯកតោភាគី នៅក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យាដោយ៖

ក. មិនតម្រូវឱ្យអ្នកប្រើប្រាស់ បញ្ជាក់អំពីមូលហេតុនៃការដកខ្លួនចេញពីកិច្ចសន្យាលក់ទិញពីចម្ងាយ និង

ខ. មិនតម្រូវឱ្យអ្នកប្រើប្រាស់ទទួលខុសត្រូវចំពោះរាល់ការចំណាយ ឬសោហ៊ុយផ្សេងៗ លើកលែងតែការចំណាយផ្សេងៗ ដូចមានចែងក្នុងប្រការ១៩ ប្រការ២០ និងប្រការ២១ នៃប្រកាសនេះ។

២. បុគ្គលធ្វើធុរកិច្ចត្រូវអនុញ្ញាតឱ្យអ្នកប្រើប្រាស់ មានសិទ្ធិដកខ្លួនចេញពីកិច្ចសន្យាលក់ទិញពីចម្ងាយតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលធ្វើធុរកិច្ច នៅក្នុងកំឡុងពេល៧(ប្រាំពីរ) ថ្ងៃប្រតិទិន។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវធ្វើឡើងដោយអនុលោមតាមប្រការ១៦ នៃប្រកាសនេះ។

៣. រាល់កិច្ចសន្យាលក់ទិញពីចម្ងាយ ដែលមិនបានចែងនូវខសន្យាទាំងឡាយណាដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ មានសិទ្ធិដកខ្លួនចេញពីកិច្ចសន្យានៅក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យា ត្រូវចាត់ទុកថាជាអំពើល្មើសលើការមិនប្រតិបត្តិតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ និងត្រូវពិន័យអន្តរការណ៍ស្របតាមមាត្រា៤៨ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

**ប្រការ៦._ កំឡុងពេលដកខ្លួនពីកិច្ចសន្យារបស់អ្នកប្រើប្រាស់សម្រាប់ការលក់ពីចម្ងាយ**

១. សម្រាប់ការផ្គត់ផ្គង់សេវា រយៈពេល៧(ប្រាំពីរ)ថ្ងៃប្រតិទិន ដូចមានចែងនៅក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវចាប់ផ្តើមរាប់បន្ទាប់ពីកាលបរិច្ឆេទនៃការចុះកិច្ចសន្យាលក់ទិញសេវា។

២. សម្រាប់ការផ្គត់ផ្គង់ទំនិញ រយៈពេល៧(ប្រាំពីរ)ថ្ងៃប្រតិទិន ដូចមានចែងនៅក្នុងប្រការ៥ នៃប្រកាសនេះត្រូវចាប់ផ្តើមរាប់បន្ទាប់ពី៖

ក. កាលបរិច្ឆេទដែលអ្នកប្រើប្រាស់ ឬបុគ្គលណាមួយដែលកំណត់ដោយអ្នកប្រើប្រាស់(ក្រៅពីអ្នកដឹកជញ្ជូន) បានទទួលទំនិញ ឬ

ខ. កាលបរិច្ឆេទដែលអ្នកប្រើប្រាស់ ឬបុគ្គលណាមួយដែលកំណត់ដោយអ្នកប្រើប្រាស់(ក្រៅពីអ្នកដឹកជញ្ជូន) បានទទួលទំនិញចុងក្រោយ សម្រាប់ប្រតិបត្តិការលក់ទិញ ឬការព្រមព្រៀងដែលតម្រូវឱ្យប្រគល់ទំនិញច្រើនដងចំពោះការបញ្ជាទិញមួយ ឬ

គ. កាលបរិច្ឆេទដែលអ្នកប្រើប្រាស់ ឬបុគ្គលណាមួយដែលកំណត់ដោយអ្នកប្រើប្រាស់(ក្រៅពីអ្នកដឹកជញ្ជូន) បានទទួលទំនិញតាមការបញ្ជាទិញចំពោះការផ្គត់ផ្គង់ច្រើនលើក។

## ជំពូកទី៣
## សិទ្ធិទទួលបានកំឡុងពេលដកខ្លួនពីកិច្ចសន្យា សម្រាប់ការលក់នៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់

**ប្រការ៧.-  សិទ្ធិដកខ្លួនរបស់អ្នកប្រើប្រាស់ពីកិច្ចសន្យាលក់ទិញនៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់**

១. ដើម្បីឱ្យអ្នកប្រើប្រាស់មានពេលវេលាគ្រប់គ្រាន់ក្នុងការពិចារណា និងសម្រេចចិត្តឡើងវិញលើការទិញទំនិញ និង/ឬសេវាណាមួយ ដែលបានលក់តាមរយៈការលក់នៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ ដោយពុំមានសម្ពាធ បុគ្គលធ្វើធុរកិច្ចនៃការលក់នៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ ត្រូវកំណត់លក្ខខណ្ឌនៅក្នុងកិច្ចសន្យាលក់ទិញ ដើម្បីឱ្យអ្នកប្រើប្រាស់មានសិទ្ធិដកខ្លួនពីកិច្ចសន្យាដោយឯកតោភាគីបាន នៅក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យាដោយៈ

ក. មិនតម្រូវឱ្យអ្នកប្រើប្រាស់ បញ្ជាក់អំពីមូលហេតុនៃការដកខ្លួនចេញពីកិច្ចសន្យាលក់ទិញនៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ និង

ខ. មិនតម្រូវឱ្យអ្នកប្រើប្រាស់ទទួលខុសត្រូវចំពោះរាល់ការចំណាយ ឬសោហ៊ុយផ្សេងៗ លើកលែងតែការចំណាយផ្សេងៗ ដូចមានចែងក្នុងប្រការ១៩ ប្រការ២០ និងប្រការ២១ នៃប្រកាសនេះ។

២. បុគ្គលធ្វើធុរកិច្ចត្រូវអនុញ្ញាតឱ្យអ្នកប្រើប្រាស់ មានសិទ្ធិដកខ្លួនចេញពីកិច្ចសន្យាលក់ទិញនៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលធ្វើធុរកិច្ច នៅក្នុងកំឡុងពេល៧(ប្រាំពីរ)ថ្ងៃប្រតិទិន។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវធ្វើឡើងដោយអនុលោមតាមប្រការ១៦ នៃប្រកាសនេះ។

៣. រាល់កិច្ចសន្យាលក់ទិញនៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ ដែលមិនចែងនូវខសន្យាទាំងឡាយណាដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ មានសិទ្ធិដកខ្លួនចេញពីកិច្ចសន្យានៅក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យា ត្រូវចាត់ទុកថាជាអំពើល្មើសលើការមិនប្រតិបត្តិតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ និងត្រូវពិន័យអន្តរការណ៍ស្របតាមមាត្រា៤៨ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

**ប្រការ៨.-  កំឡុងពេលដកខ្លួនពីកិច្ចសន្យារបស់អ្នកប្រើប្រាស់សម្រាប់ការលក់នៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់**

រយៈពេល៧(ប្រាំពីរ)ថ្ងៃប្រតិទិន ដូចមានចែងនៅក្នុងប្រការ៧ នៃប្រកាសនេះ ត្រូវរាប់បន្ទាប់ពីកាលបរិច្ឆេទនៃការចុះកិច្ចសន្យាលក់ទិញនៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់។

## ជំពូកទី៤
## ករណីលើកលែងចំពោះសិទ្ធិដកខ្លួនពីកិច្ចសន្យា

**ប្រការ៩.-  ករណីលើកលែងចំពោះការលក់បន្ទាប់ពីការប្រើប្រាស់សាកល្បង**

កំឡុងពេលដកខ្លួនពីកិច្ចសន្យា មិនត្រូវយកមកអនុវត្ត ប្រសិនបើបុគ្គលធ្វើធុរកិច្ចផ្តល់ការលក់ បន្ទាប់ពីការប្រើប្រាស់សាកល្បង ដោយអនុលោមតាមមាត្រា៥២០ នៃក្រមរដ្ឋប្បវេណី។

**ប្រការ១០.- ករណីលើកលែងចំពោះការលក់ទំនិញមួយចំនួន**

កំឡុងពេលដកខ្លួនពីកិច្ចសន្យា មិនត្រូវយកមកអនុវត្ត ចំពោះការលក់ទំនិញរវាងបុគ្គលធ្វើធុរកិច្ច និងអ្នកប្រើប្រាស់ ក្នុងករណីដូចខាងក្រោម៖

ក. តម្លៃនៃការផ្គត់ផ្គង់ទំនិញ ប្រែប្រួលអាស្រ័យលើទីផ្សារហិរញ្ញវត្ថុ ដែលបុគ្គលធ្វើធុរកិច្ចមិនអាចគ្រប់គ្រងបាន និងដែលអាចកើតឡើងនៅក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យា។

ខ. ការផ្គត់ផ្គង់ទំនិញធ្វើឡើងតាមការបញ្ជាទិញជាពិសេសរបស់អ្នកប្រើប្រាស់ ដែលទំនិញនោះជាទំនិញដែលមិនបានផលិតទុកជាមុន ហើយត្រូវផលិតផ្អែកតាមការបញ្ជាទិញ ការជ្រើសរើស ឬការសម្រេចចិត្តរបស់អ្នកប្រើប្រាស់។

គ. ទំនិញដែលឆាប់ផុតកំណត់ សំដៅដល់ទំនិញដែលមានអាយុកាលខ្លីសម្រាប់ការប្រើប្រាស់ ដោយមិនលើសពីរយៈពេល៣០ (សាមសិប)ថ្ងៃប្រតិទិន។

ឃ. ទំនិញងាយខូចគុណភាព សំដៅដល់ទំនិញណាមួយដែលគុណភាពរបស់វាធ្លាក់ចុះ ដោយសារលក្ខខណ្ឌអាកាសធាតុ ហើយមានអាយុកាលខ្លីសម្រាប់ការប្រើប្រាស់មិនលើសពី៣០ (សាមសិប)ថ្ងៃប្រតិទិន។

ង. ទំនិញដែលត្រូវបានហែកសំបកដោយអ្នកប្រើប្រាស់បន្ទាប់ពីការប្រគល់ និងមិនអាចទទួលយកវិញបាន ដោយសារមូលហេតុអនាម័យ ឬការការពារសុខភាព។

ច. ការផ្គត់ផ្គង់ភេសជ្ជៈ។

ឆ. ការផ្គត់ផ្គង់ អូឌីយ៉ូ ឬវីដេអូ ឬកម្មវិធីកុំព្យូទ័រ ដែលត្រូវបានហែកសំបកដោយអ្នកប្រើប្រាស់ បន្ទាប់ពីការប្រគល់។

ជ. ការផ្គត់ផ្គង់កាសែត ខិត្តប័ណ្ណ ឬទស្សនាវដ្តី លើកលែងតែការចុះកិច្ចសន្យាលក់ទិញជាប្រចាំ ចំពោះការបោះពុម្ពផ្សាយនោះ។

ឈ. កិច្ចសន្យាដែលបានចុះនៅពេលលក់ដេញថ្លៃជាសាធារណៈ។

ញ. ការផ្គត់ផ្គង់មាតិកាឌីជីថល (អក្សរ) ដែលមិនបានផ្ទុកនៅក្នុងឧបករណ៍ផ្ទុកជាក់ស្តែង និងមានការចាប់ផ្តើមប្រើប្រាស់ បន្ទាប់ពីទទួលបានការយល់ព្រមពីអ្នកប្រើប្រាស់ជាមុន និងជាលាយលក្ខណ៍អក្សរក្នុងការបោះបង់សិទ្ធិ។

ដ. រាល់កិច្ចសន្យាដែលមានទឹកប្រាក់មិនលើសពី ២០០ ០០០(ពីរសែនពាន់)រៀល។ និង

ឋ. អំណោយ និង/ឬទំនិញបញ្ចុះតម្លៃ។

**ប្រការ១១.- ករណីលើកលែងចំពោះការលក់សេវាមួយចំនួន**

កំឡុងពេលដកខ្លួនពីកិច្ចសន្យា មិនត្រូវយកមកអនុវត្តចំពោះការលក់សេវារវាងបុគ្គលធ្វើធុរកិច្ចនិងអ្នកប្រើប្រាស់ ក្នុងករណីដូចខាងក្រោម៖

ក. សេវាដែលបានផ្តល់ទាំងស្រុង នៅមុនពេលបញ្ចប់កំឡុងពេលដកខ្លួនពីកិច្ចសន្យា ដោយទទួលបានការយល់ព្រមពីអ្នកប្រើប្រាស់ជាមុន និងការលះបង់សិទ្ធិអនុវត្តកំឡុងពេលដកខ្លួនពីកិច្ចសន្យារបស់អ្នកប្រើប្រាស់នៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ។

ខ. តម្លៃនៃការផ្គត់ផ្គង់សេវា ប្រែប្រួលអាស្រ័យលើទីផ្សារហិរញ្ញវត្ថុ ដែលបុគ្គលធ្វើធុរកិច្ចមិនអាចគ្រប់គ្រងបាន និងដែលអាចកើតឡើងនៅក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យា។

គ. ការងារថែទាំ ឬជួសជុល ដែលបានបំពេញបន្ទាន់ នៅលំនៅដ្ឋានរបស់អ្នកប្រើប្រាស់ និងមានការស្នើសុំជាក់លាក់ពីអ្នកប្រើប្រាស់ក្នុងការផ្លាស់ប្តូរគ្រឿងបន្លាស់។

ឃ. ការផ្តល់សេវាស្នាក់នៅ សេវាដឹកជញ្ជូនទំនិញ ការជួលរថយន្ត សេវាម្ហូបអាហារ ឬសកម្មភាពកម្សាន្ត ដែលត្រូវផ្តល់ជូននូវកាលបរិច្ឆេទ ឬកំឡុងពេលជាក់លាក់មួយ

ង. រាល់សេវានៅក្នុងវិស័យធនាគារ។ និង

ច. រាល់កិច្ចសន្យាដែលមានទឹកប្រាក់មិនលើសពី ២០០ ០០០(ពីររយពាន់) រៀល។

## ជំពូកទី៥
## ករណីយកិច្ចរបស់បុគ្គលធ្វើធុរកិច្ច

### ប្រការ១២.- ករណីយកិច្ចផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់

១. បុគ្គលធ្វើធុរកិច្ចត្រូវផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់ អំពីសិទ្ធិនៃកំឡុងពេលដកខ្លួនពីកិច្ចសន្យារបស់អ្នកប្រើប្រាស់។

២. ដើម្បីអនុវត្តកាតព្វកិច្ចដូចបានកំណត់ខាងលើ មុនចុះកិច្ចសន្យាលក់ទិញពីចម្ងាយនិងកិច្ចសន្យាលក់ទិញនៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ បុគ្គលធ្វើធុរកិច្ចត្រូវពន្យល់និងផ្តល់ជូនអ្នកប្រើប្រាស់នូវៈ

ក. ទម្រង់នៃការសុំដកខ្លួនចេញពីកិច្ចសន្យា ឬទម្រង់នៃការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដើម្បីស្នើសុំដកខ្លួនចេញពីកិច្ចសន្យា ដោយមានការពន្យល់អំពីរបៀបដាក់និងបញ្ជូនទម្រង់នោះទៅឱ្យបុគ្គលធ្វើធុរកិច្ច។

ខ. ការកំណត់អំពីអត្តសញ្ញាណរបស់បុគ្គលធ្វើធុរកិច្ច និងមធ្យោបាយទំនាក់ទំនងជាមួយបុគ្គលធ្វើធុរកិច្ចស្របតាមបទប្បញ្ញត្តិស្តីពីបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់។ ដើម្បីអនុវត្តសិទ្ធិនៃកំឡុងពេលដកខ្លួនពីកិច្ចសន្យារបស់អ្នកប្រើប្រាស់ បុគ្គលធ្វើធុរកិច្ចអាចស្នើសុំឱ្យអ្នកប្រើប្រាស់បំពេញនិងផ្ញើជូននូវទម្រង់នៃការដកខ្លួនចេញពីកិច្ចសន្យាតាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬតាមមធ្យោបាយផ្សេងទៀតដែលអាចទទួលយកបាន។

គ. កិច្ចសន្យានិងលក្ខខណ្ឌគុណភាពនៃទំនិញដែលត្រូវប្រគល់ត្រឡប់ ត្រូវស្ថិតក្នុងស្ថានភាពសមស្របសម្រាប់បុគ្គលធ្វើធុរកិច្ចអាចដាក់លក់វិញបាននៅក្នុងទីផ្សារ ដូចទំនិញដែលមិនទាន់បានប្រើប្រាស់។ និង

ឃ. ព័ត៌មានអំពីសោហ៊ុយសម្រាប់ការប្រគល់ទំនិញ និង/ឬសេវាត្រឡប់មកវិញ ដូចមានចែងនៅក្នុងប្រការ ១៩ និងប្រការ២១ នៃប្រកាសនេះ។

### ប្រការ១៣.- ករណីបុគ្គលធ្វើធុរកិច្ចមិនអនុវត្តកាតព្វកិច្ច

ក្នុងករណីបុគ្គលធ្វើធុរកិច្ចមិនបានផ្តល់ព័ត៌មានជូនអ្នកប្រើប្រាស់ ដូចមានចែងនៅក្នុងប្រការ១២ នៃប្រកាសនេះ រយៈពេល៧ (ប្រាំពីរ)ថ្ងៃប្រតិទិនឬកំឡុងពេលដកខ្លួនពីកិច្ចសន្យា មិនត្រូវចាប់ផ្តើមរាប់រហូតដល់កាលបរិច្ឆេទដែលព័ត៌មានតម្រូវទាំងនោះត្រូវបានផ្តល់ជូនអ្នកប្រើប្រាស់។

### ប្រការ១៤.- ការសងថ្លៃលក់ត្រឡប់

១. ក្នុងករណីដែលសិទ្ធិនៃកំឡុងពេលដកខ្លួនពីកិច្ចសន្យាត្រូវបានអនុវត្តចំពោះការលក់ទិញទំនិញ បុគ្គលធ្វើធុរកិច្ច ត្រូវប្រគល់ថ្លៃលក់ទាំងអស់ត្រឡប់ទៅឱ្យអ្នកប្រើប្រាស់វិញមិនឱ្យលើសពីរយៈពេល៧ (ប្រាំពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទដែលបុគ្គលធ្វើធុរកិច្ចបានទទួលទំនិញពីអ្នកប្រើប្រាស់វិញ។

២. ក្នុងករណីដែលសិទ្ធិនៃកំឡុងពេលដកខ្លួនពីកិច្ចសន្យាត្រូវបានអនុវត្តចំពោះការផ្តល់សេវា បុគ្គលធ្វើធុរកិច្ច ត្រូវប្រគល់ថ្លៃលក់ទាំងអស់ លើកលែងតែសោហ៊ុយចំពោះការប្រើប្រាស់សេវា ដូចមានចែងក្នុងប្រការ២១ នៃប្រកាសនេះ ត្រឡប់ទៅឱ្យអ្នកប្រើប្រាស់វិញមិនឱ្យលើសពីរយៈពេល៧ (ប្រាំពីរ)ថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទដែលបុគ្គលធ្វើធុរកិច្ច បានទទួលការជូនដំណឹងពីការសម្រេចចិត្តរបស់អ្នកប្រើប្រាស់ក្នុងការដកខ្លួនចេញពីកិច្ចសន្យាផ្តល់សេវានោះ។

៣. ការខកខានប្រគល់ថ្លៃលក់ទំនិញទាំងអស់ទៅឱ្យអ្នកប្រើប្រាស់ក្នុងកំឡុងពេល៧ (ប្រាំពីរ)ថ្ងៃប្រតិទិន ដូចមានចែងក្នុងប្រការនេះ ត្រូវចាត់ទុកជាការអនុវត្តមិនសុចរិត និងត្រូវពិន័យអន្តរការណ៍ស្របតាមមាត្រា៤៤ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

**ប្រការ១៥.- ការដកខ្លួនចេញពីកិច្ចសន្យាដោយមិនមានលក្ខខណ្ឌសំណងការខូចខាត**

១. ក្នុងខសន្យាដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ មានសិទ្ធិដកខ្លួនចេញពីកិច្ចសន្យាដោយឯកតោភាគី នៅក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យា បុគ្គលធ្វើធុរកិច្ចមិនត្រូវដាក់លក្ខខណ្ឌឱ្យអ្នកប្រើប្រាស់ផ្តល់សំណង ចំពោះការខូចខាតដល់បុគ្គលធ្វើធុរកិច្ច នៅពេលដែលអ្នកប្រើប្រាស់ដកខ្លួនពីកិច្ចសន្យាលក់ទិញពីចម្ងាយនិងកិច្ចសន្យាលក់ទិញនៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ លើកលែងតែមានការចែងផ្សេងដោយបទប្បញ្ញត្តិនៃប្រកាសនេះ។

២. ការដាក់លក្ខខណ្ឌដោយបុគ្គលធ្វើធុរកិច្ច ឱ្យអ្នកប្រើប្រាស់ផ្តល់សំណងចំពោះការខូចខាតដល់បុគ្គលធ្វើធុរកិច្ច នៅពេលដែលអ្នកប្រើប្រាស់ដកខ្លួនពីកិច្ចសន្យាលក់ទិញពីចម្ងាយ និងកិច្ចសន្យាលក់ទិញនៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ ត្រូវចាត់ទុកជាការអនុវត្តមិនសុចរិត និងត្រូវពិន័យអន្តរការណ៍ស្របតាមមាត្រា៤៤ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

## ជំពូកទី៦
## ករណីយកិច្ចរបស់អ្នកប្រើប្រាស់

**ប្រការ១៦.- ករណីយកិច្ចក្នុងការជូនដំណឹងទៅបុគ្គលធ្វើធុរកិច្ច**

១. នៅមុនពេលផុតកំណត់នៃកំឡុងពេលដកខ្លួនពីកិច្ចសន្យា អ្នកប្រើប្រាស់អាចដកខ្លួនចេញពីកិច្ចសន្យាលក់ទិញទំនិញ និង/ឬសេវា តាមរយៈការលក់ពីចម្ងាយ ឬការលក់នៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលធ្វើធុរកិច្ច ស្របតាមព័ត៌មាននិងនីតិវិធីដែលបានផ្តល់និងពន្យល់ដោយបុគ្គលធ្វើធុរកិច្ច ដូចមានចែងនៅក្នុងប្រការ១២ នៃប្រកាសនេះ។

២. ក្នុងករណីបុគ្គលធ្វើធុរកិច្ចមិនបានផ្តល់ ឬពន្យល់អំពីនីតិវិធីទំនាក់ទំនង ឬនីតិវិធីនៃការជូនដំណឹងទៅអ្នកប្រើប្រាស់ ក្នុងការអនុវត្តសិទ្ធិនៃកំឡុងពេលដកខ្លួនពីកិច្ចសន្យា រាល់ការជូនដំណឹងអំពីការដកខ្លួនចេញពីកិច្ចសន្យា ត្រូវចាត់ទុកថាបានផ្ញើជូនបុគ្គលធ្វើធុរកិច្ច នៅពេលការជូនដំណឹងនោះត្រូវបានផ្ញើទៅដល់ទីតាំង ឬអាសយដ្ឋានអេឡិចត្រូនិក ដែលផ្តល់ដោយបុគ្គលធ្វើធុរកិច្ច ឬបានបង្ហាញនៅក្នុងប្រភពជាសាធារណៈ រួមមានវិបសាយរបស់បុគ្គលធ្វើធុរកិច្ចឬក្រសួងពាណិជ្ជកម្ម។

៣. វិធាននៃការបញ្ជូននិងការទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបកស្រាយដោយអនុលោមតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**ប្រការ១៧.- បន្ទុកនៃភស្តុតាង**

អ្នកប្រើប្រាស់ត្រូវមានភស្តុតាងបញ្ជាក់អំពីការជូនដំណឹងស្តីពីការដកខ្លួនពីកិច្ចសន្យា ដែលបានធ្វើឡើងនៅក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យា ចំពោះកិច្ចសន្យាលក់ទិញទំនិញ និង/ឬសេវា តាមរយៈការលក់ពីចម្ងាយ ឬការលក់នៅទីតាំងផ្ទាល់របស់អ្នកប្រើប្រាស់។

**ប្រការ១៨.- ការប្រគល់ទំនិញត្រឡប់**

១. ប្រសិនបើអ្នកប្រើប្រាស់បានអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងកំឡុងពេលដកខ្លួនពីកិច្ចសន្យាចំពោះការលក់ទំនិញ អ្នកប្រើប្រាស់ត្រូវប្រគល់ទំនិញទៅឱ្យបុគ្គលធ្វើធុរកិច្ចឬបុគ្គលណាមួយដែលកំណត់ដោយបុគ្គលធ្វើធុរកិច្ចវិញភ្លាមៗ នៅពេលដែលអ្នកប្រើប្រាស់ទទួលបានថ្លៃលក់សរុបមកវិញ។

២. ក្នុងករណីដែលការទូទាត់ឬការផ្លាស់ប្តូរភ្លាមៗមិនអាចធ្វើទៅបាន អ្នកប្រើប្រាស់ត្រូវប្រគល់ទំនិញទៅឱ្យបុគ្គលធ្វើធុរកិច្ចវិញ ដោយពុំឱ្យលើសពីរយៈពេល៧(ប្រាំពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទដែលការជូនដំណឹងអំពីការដកខ្លួនចេញពីកិច្ចសន្យានេះ បានបញ្ជូនទៅដល់បុគ្គលធ្វើធុរកិច្ច។

**ប្រការ១៩.- សោហ៊ុយចំពោះការប្រគល់ទំនិញត្រឡប់**

១. អ្នកប្រើប្រាស់ត្រូវទទួលខុសត្រូវចំពោះ៖

ក. សោហ៊ុយដោយផ្ទាល់ដែលកើតចេញពីការប្រគល់ទំនិញត្រឡប់ លើកលែងតែក្នុងករណីដែលទំនិញមិនស្របតាមកិច្ចសន្យាលក់ទិញរវាងអ្នកប្រើប្រាស់និងបុគ្គលធ្វើធុរកិច្ច។

ខ. រាល់ការធ្លាក់ថ្លៃនៃទំនិញដែលបណ្តាលមកពីអំពើណាមួយរបស់អ្នកប្រើប្រាស់ ដែលធ្វើឱ្យទំនិញខូច ឬមិនអនុលោមតាមកិច្ចសន្យា និងលក្ខខណ្ឌសមស្របដែលបានកំណត់ដោយបុគ្គលធ្វើធុរកិច្ច។

២. ទោះបីជាបានចែងដូចមានរៀបរាប់ខាងលើក៏ដោយ ប្រសិនបើបុគ្គលធ្វើធុរកិច្ចយល់ព្រមទទួលខុសត្រូវចំពោះសោហ៊ុយខាងលើ ឬមិនបានផ្តល់ដំណឹងដល់អ្នកប្រើប្រាស់អំពីសោហ៊ុយខាងលើជាមុន ឬនៅពេលចុះហត្ថលេខាលើកិច្ចសន្យាលក់ទិញទំនិញនោះ បុគ្គលធ្វើធុរកិច្ចត្រូវទទួលខុសត្រូវចំពោះរាល់ការចំណាយខាងលើ។

**ប្រការ២០.- ការទទួលខុសត្រូវចំពោះទំនិញដែលខូចខាតធ្ងន់ធ្ងរ**

អ្នកប្រើប្រាស់ត្រូវបាត់បង់សិទ្ធិនៃកំឡុងពេលដកខ្លួនពីកិច្ចសន្យា ប្រសិនបើទំនិញខូចខាតធ្ងន់ធ្ងរ ឬមិនអាចដាក់លក់នៅក្នុងទីផ្សារឡើងវិញបាន ដោយសារអ្នកប្រើប្រាស់បានប្រើប្រាស់ទំនិញ ឬធ្វើឱ្យទំនិញខូចខាតដោយមិនបានអនុលោមតាមកិច្ចសន្យា និងលក្ខខណ្ឌសមស្របដែលបានកំណត់ដោយបុគ្គលធ្វើធុរកិច្ច។

**ប្រការ២១.- សោហ៊ុយចំពោះការប្រើប្រាស់សេវា**

ចំពោះកិច្ចសន្យាផ្តល់សេវា អ្នកប្រើប្រាស់ត្រូវទទួលខុសត្រូវចំពោះសោហ៊ុយលើសេវា ដែលបានប្រើប្រាស់ ឬបម្រើជូនអ្នកប្រើប្រាស់រហូតដល់កាលបរិច្ឆេទ៖

ក. ការជូនដំណឹងអំពីការដកខ្លួនចេញពីកិច្ចសន្យា ត្រូវបានផ្ញើទៅដល់បុគ្គលធ្វើធុរកិច្ច។

ខ. នៅចុងបញ្ចប់នៃរយៈពេលណាមួយ ដោយមិនលើសពីរយៈពេល១ (មួយ)ខែ ក្នុងកិច្ចសន្យានិងលក្ខខណ្ឌសមស្របដែលត្រូវបានកំណត់ដោយបុគ្គលធ្វើធុរកិច្ចដើម្បីបញ្ចប់ការផ្តល់សេវាកម្មខាងលើ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**ប្រការ២២.-**

ក្នុងរយៈពេល ៦(ប្រាំមួយ)ខែ បន្ទាប់ពីប្រកាសនេះចូលជាធរមាន បុគ្គលធ្វើធុរកិច្ចត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសនេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ២៣.-** និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤.-** ការអនុវត្ត

សមាសភាពនៃគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១០កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ